# ជម្រើសរបស់លីឡា

លីឡាចង់ជ្រើសរើសត្រូវ ។



ដោយ ខារ៉ូឡាញណា ម៉ារីន
( ផ្អែកទៅលើដំណើររឿងពិត )

« *ព្រះបានប្រទានវិហារឲ្យខ្ញុំ* » ( សៀវភៅចម្រៀងកុមារ *ទំព័រ ៧៣* ) ។

« ដល់ពេលអានព្រះគម្ពីរហើយ ! » លីឡាបាននិយាយ ។ លីឡាចូលចិត្តអានឲ្យអានីកាជាប្អូនស្រីនាង និងស្វេថានជាប្អូនប្រុសនាងស្តាប់ ។ មិនយូរទៀតទេលីឡានឹងទទួលបុណ្យជ្រមុជទឹក ! ដើម្បីត្រៀមខ្លួនជាស្រេច នាងចង់អានព្រះគម្ពីរជារៀងរាល់ថ្ងៃ ។

លីឡាបានបើកសៀវភៅរឿងព្រះគម្ពីរទៅទំព័រទីមួយ ។ អានីកា និងស្វេថានបានខិតមកជិតដើម្បីពួកគេអាចមើលឃើញរូបភាព ។

លីឡាបាននិយាយថា « ចូរស្តាប់ដោយប្រុងប្រយ័ត្ន ព្រោះបងនឹងសួរសំណួរដល់ប្អូនៗបន្ទាប់ពីអានហើយ » ។ បន្ទាប់មកនាងបានចាប់ផ្តើមអានជំពូកទីមួយ ។

លីឡាបានអានថា « មុនពេលយើងកើតមក យើងបានរស់នៅឯស្ថានសួគ៌ » ។ « យើងពុំទាន់មានរូបកាយនៅឡើយទេ ។ យើងគឺជាវិញ្ញាណ » ។

លីឡា អានីកា និងស្វេថាន បានមើលទៅរូបភាពដែលមានមនុស្សស្លៀកពាក់ពណ៌ស ។

« ត្រៀមសម្រាប់សំណួរទីមួយហើយឬនៅ ? » លីឡាបានងាកទៅអានីកា ។ « តើប្អូនបានមកពីណាមុនប្អូនកើតមក ? »

អានីកាបានទះដៃនាង ។ « ស្ថានសួគ៌ ! »

លីឡាបាននិយាយថា « ត្រឹមត្រូវហើយ » ។ « ហើយតើស្វេថានបានមកពីណាដែរ ? »

អានីកាបាននិយាយថា « គាត់បានមកពីស្ថានសួគ៌ផងដែរ » ។ ស្វេថានបានសើចកក្អឹក ហើយបានដាក់ដៃចូលមាត់គាត់ ។ លីឡា និងអានីកាបានសើច ។ ស្វេថានគឺជាក្មេងអាយុមួយឆ្នាំដែលគួរឲ្យស្រឡាញ់បំផុតនៅក្នុងប្រទេសអាហ្សង់ទីន !

លីឡាបាននិយាយថា « គ្រួសារយើងទាំងមូលបានមកពីស្ថានសួគ៌ » ។ « ព្រះយេស៊ូវផងដែរ ។ ទ្រង់បានយាងមកដើម្បីជួយយើង ដើម្បីយើងអាចរស់នៅជាមួយព្រះវរបិតាសួគ៌ម្តងទៀត » ។ លីឡាបានចង្អុលទៅរូបភាពព្រះយេស៊ូវនៅក្នុងទំព័រនោះ ។

បន្ទាប់ពីនាងបានអានចប់ហើយ លីឡាបន្តគិតថាវាមានសភាពបែបណាដើម្បីរស់នៅជាមួយព្រះយេស៊ូវនៅក្នុងស្ថានសួគ៌នោះ ។ នាងចង់ក្លាយដូចជាទ្រង់ ។ នាងចង់ជ្រើសរើសត្រូវជានិច្ច !

នៅថ្ងៃបន្ទាប់នៅសាលារៀន លីឡាកូរពោះពេលនាងឈរក្នុងជួររង់ចាំអាហារពេលព្រឹក ។ នាងស្ទើរតែអាចភ្លក់រសជាតិនំអិមផាញ៉ាដាសបាន ពេលដែល Señora Ruiz បានដាក់វាក្នុងចាននាង ។ វាឈ្ងុយខ្លាំងណាស់ !

បន្ទាប់មក Señora Ruiz បានចាក់ទឹកដោះគោមួយកែវឲ្យលីឡា ។

រចនារូបភាពដោយ អាលេស្សា ប៊្រីកសូល

លីឡាបានគិត *អូ* ។ ទឹកដោះគោមើលទៅមានពណ៌ក្រមៅជាងសព្វដង ។ ជួនកាលសាលានាងបានថែមកាហ្វេ ឬតែទៅក្នុងភេសជ្ជៈ ។

« តើមានកាហ្វេ ឬតែនៅក្នុងទឹកដោះគោទេថ្ងៃនេះ ? » លីឡាបានសួរ ។

Señora Ruiz បានគ្រវីដៃគាត់ ។ គាត់បាននិយាយថា « មានកាហ្វេបន្តិច » ។ « ក្មួយនឹងមិនអាចដឹងរស់ជាតិវាផង » ។

លីឡាបានគិតបន្តិច ។ នាងចងចាំថានាងចង់ក្លាយដូចជាព្រះយេស៊ូវ ហើយជ្រើសរើសត្រូវ ។ នាងបានដឹងថា ការផឹកកាហ្វេជាអ្វីដែលពួកព្យាការីបានប្រាប់ថាមិនឲ្យធ្វើ ។

លីឡាបាននិយាយថា « ទេ អរគុណហើយ ។ ខ្ញុំនឹងមិនញ៉ាំទឹកដោះគោទេថ្ងៃនេះ » ។ នាងបានញញឹមដាក់ Señora Ruiz ។ បន្ទាប់មកនាងបានអង្គុយចុះដើម្បីញ៉ាំ ។

នៅយប់នោះ លីឡាបានជួយ Papi លាងចាននៅក្នុងផ្ទះបាយ ។ នាងនៅតែគិតអំពីរឿងក្នុងព្រះគម្ពីរ ។ នាងក៏បានគិតអំពីទឹកដោះគោផងដែរ ។

« Papi ? »

« បាទ ! » Papi បានតប ។

« ហេតុអ្វីព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យយើងមានរូបកាយ ? »

Papi បានគិតពេលគាត់លាងចានមួយទៀត ។ គាត់បាននិយាយថា « មែនហើយ ទ្រង់ប្រទានរូបកាយដល់យើង ដើម្បីយើងអាចក្លាយដូចជាទ្រង់ » ។ « រូបកាយរបស់កូនជាផ្ទះសម្រាប់វិញ្ញាណកូន ។ នោះជាអត្ថន័យរបស់វាពេលយើងនិយាយថា រូបកាយយើងជាព្រះវិហារបរិសុទ្ធ » ។

លីឡាបានងក់ក្បាល ។ នាងបានច្រៀងចម្រៀងមួយអំពីរឿងនោះនៅក្នុងថ្នាក់កុមារនាពេលខ្លះ ! « ដូច្នេះហើយបានជាព្រះវរបិតាសួគ៌មានព្រះទ័យចង់ឲ្យយើងថែរក្សារូបកាយរបស់យើង មែនទេ ? »

Papi បានតបថា « មែនហើយ » ។

លីឡាបាននិយាយថា « ថ្ងៃនេះនៅឯសាលា គេបានដាក់កាហ្វេនៅក្នុងទឹកដោះគោ ។ « ខ្ញុំអត់បានផឹកវាទេ ។ ខ្ញុំព្យាយាមដើម្បីថែទាំព្រះវិហារបរិសុទ្ធរបស់ខ្ញុំ » ។

Papi បាននិយាយថា « ប៉ាមានមោទនភាពចំពោះកូនណាស់ » ។ គាត់ជូតដៃគាត់នឹងកន្សែង ហើយបានឱបលីឡា ។

លីឡាបានឱប Papi យ៉ាងណែន ។ នាងសប្បាយចិត្តដែលបានថែរក្សារូបកាយដែលព្រះវរបិតាសួគ៌បានប្រទានដល់នាង ។ ●

*អ្នកនិពន្ធរស់នៅទីក្រុងកូរីនទេស ប្រទេសអាហ្សង់ទីន ។*

គ្រួសារនៅក្នុងរឿងនេះរស់នៅប្រទេសអាហ្សង់ទីន ។ សូមអានអត្ថបទបន្ទាប់ទៀតដើម្បីរៀនបន្ថែមអំពីប្រទេសនេះ ។